ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គ.ជ.ប

# ខិត្តប័ណ្ណអំពាវនាវ

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**សូមអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋខ្មែរត្រង់ៗដែលមានសិទ្ធិបោះឆ្នោតអញ្ជើញទៅពិនិត្យមើលឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅតាមសាលាឃុំ សង្កាត់ ដែលបងប្អូនកំពុងរស់នៅ ចាប់ពីថ្ងៃទី ១៥ ខែ កញ្ញា ដល់ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៧ ខាងមុខនេះឱ្យបានត្រប់ត្លា ។**

១- ចំពោះបងប្អូនប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៅឃុំ សង្កាត់ របស់ខ្លួនរួចហើយ សូមអញ្ជើញទៅពិនិត្យមើលឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតចុងក្រោយ គឺបញ្ជីបោះឆ្នោតឆ្នាំ២០០៦ និងទម្រង់១០២៥ ដែលជាបញ្ជីស្រង់ឈ្មោះអ្នកបោះឆ្នោតត្រៀមដើម្បីលុបចេញពីបញ្ជីបោះឆ្នោតដោយមូលហេតុស្លាប់ឬផ្លាស់ប្តូរទីលំនៅចេញពីឃុំ សង្កាត់ ឬឈ្មោះស្ទួន ឬមូលហេតុផ្សេងទៀតតម្រូវដោយច្បាប់ដែលត្រូវបិទផ្សាយជាសាធារណៈនៅសាលាឃុំ សង្កាត់ ចាប់ពីថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ២០០៧ ។

- ក្នុងករណីពិនិត្យមើលក្នុងបញ្ជីបោះឆ្នោតឃើញមានខុសទិន្នន័យក្នុងចំណុចណាមួយ ដូចជាឈ្មោះភេទ ថ្ងៃខែឆ្នាំកំណើត ទីលំនៅ សូមអញ្ជើញទៅជួបស្មៀនឃុំ សង្កាត់ ដើម្បីសុំ កែតម្រូវ ចាប់ពីថ្ងៃទី ១៥ ខែ កញ្ញា រហូតដល់ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៧ ខាងមុខនេះ ឱ្យបានទាន់ ពេលវេលា ។
- ក្នុងករណីពិនិត្យមើលក្នុងទម្រង់១០២៥ ឃើញមានឈ្មោះរបស់បងប្អូនផ្ទាល់ ឬឈ្មោះរបស់ញាតិមិត្ត តែឈ្មោះទាំងនោះពុំស្ថិតក្នុងករណីណាមួយតម្រូវអោយលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតទេនោះ សូមអញ្ជើញទៅជួបស្មៀនឃុំ សង្កាត់នៅក្នុងរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតដូចខាងលើដើម្បីតាំងឱ្យស្មៀន ក្រុមប្រឹក្សាឃុំ សង្កាត់ ដកឈ្មោះចេញពីទម្រង់ ១០២៥ ។

២- ចំពោះបងប្អូនដែលទើបផ្លាស់ប្តូរទីលំនៅចូលពីឃុំ សង្កាត់ផ្សេង អ្នកពុំធ្លាប់បានចុះឈ្មោះ អ្នកទើបគ្រប់ អាយុ ១៨ ឆ្នាំ គិតដល់ថ្ងៃបោះឆ្នោត ( ២៧ ខែ កក្កដា ឆ្នាំ ២០០៨ ) សូមអញ្ជើញទៅសុំចុះឈ្មោះដោយផ្ទាល់នៅតាមសាលាឃុំ សង្កាត់ ឬនៅទីតាំងណាមួយក្នុងឃុំ សង្កាត់ដែលបងប្អូនកំពុងរស់នៅ ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតដូចខាងលើ ដោយត្រូវយកទៅជាមួយនូវឯកសារមួយ ឬច្រើនដែលអាចបញ្ជាក់លក្ខខណ្ឌ ៨យ៉ាង គឺ ៖ អត្តសញ្ញាណ - សញ្ជាតិ - អាយុ និងទីលំនៅ ។

★ **សូមបញ្ជាក់ថា ៖**

- ឯកសារមួយ ឬច្រើនដែលអាចបញ្ជាក់លក្ខខណ្ឌ ៨យ៉ាង ក្នុងការចុះឈ្មោះបោះឆ្នោតបានមាន ៖ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ - អត្តសញ្ញាណប័ណ្ណនគរបាលជាតិ - អត្តសញ្ញាណប័ណ្ណកងយោធពលខេមរភូមិន្ទ - លិខិតឆ្លងដែន - លិខិតសំគាល់ខ្លួនចេញដោយក្រសួងស្ថាប័នរដ្ឋ - អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិល - ឆាយាគណៈមហានិកាយ - សុទ្ធិប័ត្រគណៈធម្មយុត្តិកនិកាយ - សង្ឃដីកា - សៀវភៅគ្រួសារមានបិទរូបថតសាមីជនសំបុត្រកំណើត - លិខិតធានាអះអាងពីអត្តសញ្ញាណ អាយុ និងទីលំនៅ (ទម្រង់ ១០១៨) ជាដើម ។
- ដើម្បីបានលិខិតបញ្ជាក់អត្តសញ្ញាណ អាយុ និងទីលំនៅ (ទម្រង់ ១០១៨) បងប្អូនត្រូវយករូបថត ៤ X ៦ ពីរសន្លឹក និងរកអ្នកធានា ២នាក់ ដែលមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំ សង្កាត់ ជាមួយគ្នាដើម្បីធានានៅចំពោះមុខមេឃុំ ចៅសង្កាត់ ដើម្បីសុំចុះឈ្មោះនោះជាការស្រេច ។

**ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត**

**ចាប់ពីថ្ងៃទី ១៥ ខែ កញ្ញា ដល់ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៧**